AMRO
ASEAN +3 MACROECONOMIC RESEARCH OFFICE

10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

# របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ឆ្នាំ ២០១៨
# ASEAN+3 Regional Economic Outlook (AREO) 2018
# សេចក្តីសង្ខេប

## ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

ទស្សនវិស័យសេដ្ឋកិច្ចសកល ទាំងក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូត-លាស់ មានលក្ខណៈល្អប្រសើរជាងមុន ខណៈដែលអត្រាអតិផរណាមានការកើនឡើង។ ចំពោះសហរដ្ឋអាមេរិក សេដ្ឋកិច្ចមានកំណើនរឹងមាំ ហើយជាមួយគ្នានេះដែរសម្ពាធថ្លៃទំនិញមានការកើនឡើង តាមរយៈការបង្កើនកញ្ចប់ចំណាយសារពើពន្ធសម្រាប់ជំរុញកំណើនដោយសារការកាត់បន្ថយអត្រាពន្ធ ស្របពេលដែលចំណាយសារពើពន្ធត្រូវបានរំពឹងថានឹងបន្តកើនឡើង ទាំងក្នុងឆ្នាំនេះ និងនាពេលអនាគត។ ចំណែកឯតំបន់ចាយប្រាក់អឺរ៉ូវិញ សន្ទុះនៃការងើបឡើងវិញនៃវដ្តកំណើនសេដ្ឋកិច្ចមានការកើនឡើងលើសពីការរំពឹងទុក ដែលទ្រទ្រង់ដោយកំណើននៃតម្រូវការក្នុងវិស័យឯកជន។ ផ្ទុយទៅវិញ សេដ្ឋកិច្ចចក្រភពអង់គ្លេសមានកំណើនយឺតដោយសារភាពមិនប្រាកដប្រជានៃការដកខ្លួនចេញពីសហភាពអឺរ៉ុប (Brexit uncertainty)។

ពាណិជ្ជកម្ម និងតម្រូវការសកលមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃតម្រូវការផលិតផលសឺមីកុងឌុចទ័រ (semiconductor) និងចំណាយមូលធន។ សូចនាករនៃវិស័យបច្ចេកវិទ្យាដែលរួមមានការលក់ផលិតផលសឺមីកុងឌុចទ័របន្តរក្សាបាននូវកំណើនរឹងមាំ ដែលជួយទ្រទ្រង់ដល់ពាណិជ្ជកម្មសកល។ តម្លៃទំនិញនានា ក្នុងវិស័យថាមពល និងលោហធាតុសម្រាប់បម្រើវិស័យឧស្សាហកម្មបានងើបឡើងវិញដែលបានជួយជំរុញដល់ការនាំចេញ។

លក្ខខណ្ឌហិរញ្ញវត្ថុសកលអាចនឹងរងនូវការរឹតបន្តឹង ដោយសារធនាគារកណ្តាលសហរដ្ឋអាមេរិកបានចាប់ផ្តើមធ្វើប្រក្រតីកម្មគោលនយោបាយរូបិយវត្ថុ និងដំឡើងអត្រាការប្រាក់ ស្របពេលដែលធនាគារកណ្តាលអឺរ៉ុប (European Central Bank) កំពុងតែកាត់បន្ថយការទិញទ្រព្យសកម្ម (Quantitative Easing/Asset Purchasing Program)។ អតិផរណាបានក្លាយជាកង្វល់ជាថ្មីម្តងទៀតដល់សេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលអាចជំរុញឱ្យមានការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុកាន់តែខ្លាំងជាងមុន។ បើទោះជាមានការលក់ចេញនូវភាគហ៊ុនសកល (selloffs in global equities) កាលពីដើមខែ កុម្ភៈ ឆ្នាំ ២០១៨ ក៏ដោយ ក៏ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ក្នុងតំបន់អាស៊ានបូកបី នៅតែបន្តទទួលបាននូវលំហូរចូលនៃមូលធនសុទ្ធក្នុងទីផ្សារមូលបត្រ

របស់ខ្លួន (net capital inflows into bond markets)។ ដោយសារតំបន់នេះទទួលបាននូវលំហូរចូលនៃមូលធនយ៉ាងច្រើនសន្ធឹកសន្ធាប់ ទៅក្នុងទីផ្សារមូលបត្រតំបន់ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ តំបន់នេះគួរតែត្រួតពិនិត្យឱ្យបានដិតដល់ចំពោះហានិភ័យ និងផលប៉ះពាល់នៃលំហូរចេញនៃមូលធន ដែលបណ្តាលមកពីការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកល ឬ ការប៉ះទង្គិចដល់ទំនុកចិត្តវិនិយោគិន (confidence shock)។

កំណើនសេដ្ឋកិច្ចក្នុងតំបន់ត្រូវបានទ្រទ្រង់ដោយស្ថានភាពសេដ្ឋកិច្ចសកល ដែលមានលក្ខណៈអំណោយផលនាពេលកន្លងមក, តម្រូវការក្នុងស្រុកដែលប្រកបដោយភាពធន់ និងកំណើននៃការនាំចេញ។ ប្រទេសជាច្រើនក្នុងតំបន់ត្រូវបានវាយតម្លៃថា ស្ថិតនៅក្នុងវដ្តកំណើនសេដ្ឋកិច្ចកម្រិតកណ្តាល (mid-business cycle) ដោយសារគម្លាតទិន្នផលសេដ្ឋកិច្ច (output gap) មានទំហំតូច ប្រហាក់ប្រហែលនឹងកំណើននិន្នាការ (trend growth)។ ជាមួយនឹងស្ថានភាពសេដ្ឋកិច្ចសកលដែលមានលក្ខណៈល្អប្រសើរជាងមុន ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (AMRO) បានព្យាករកំណើនសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ក្នុងអត្រា ៥,៤% ក្នុងឆ្នាំ ២០១៨ និង ៥,២% ក្នុងឆ្នាំ ២០១៩។ សេដ្ឋកិច្ចចិន និងជប៉ុនត្រូវបានព្យាករថា នឹងមានកំណើនក្នុងអត្រា ៦,៦% និង ១,៣% រៀងគ្នា ក្នុងឆ្នាំ ២០១៨។

នាពេលដ៏ខ្លីខាងមុខ តំបន់អាស៊ានបូកបីអាចប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅចំនួនពីរ ដែលហានិភ័យនេះត្រូវបានសង្ខេបនៅក្នុងផែនទីហានិភ័យសកល (Global Risk Map) របស់ AMRO ÷

- ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុលើសពីការរំពឹងទុក តាមរយៈការដំឡើងអត្រាការប្រាក់របស់ធនាគារកណ្តាលសហរដ្ឋអាមេរិក ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃអតិផរណាក្នុងស្រុក អាចនឹងបង្កឱ្យមានប្រតិកម្មយ៉ាងខ្លាំងពីទីផ្សារហិរញ្ញវត្ថុ ប្រសិនបើសកម្មភាពគោលនយោបាយមិនត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ សេដ្ឋកិច្ចក្នុងតំបន់អាចទទួលរងផលប៉ះពាល់ តាមរយៈលំហូរចេញនៃមូលធន, ការកើនឡើងខ្ពស់ជាងមុននៃទិន្នផលមូលបត្រអធិបតេយ្យ (sovereign yields), ចំណាយលើការខ្ចីកាន់តែខ្ពស់ជាងមុន និងហានិភ័យនៃការសងបំណុល (debt refinancing risk), និង

- ភាពកាន់តែតានតឹងនៃពាណិជ្ជកម្មសកល ដោយសារការកំណត់ពន្ធនាំចូលដោយសហរដ្ឋអាមេរិកលើមុខទំនិញនាំចូលជាច្រើនពីដៃគូពាណិជ្ជកម្មសំខាន់ៗក្នុងតំបន់អាស៊ានបូកបី ដែលកត្តានេះអាចនឹងជះឥទ្ធិពលអវិជ្ជមានដល់កំណើននៃការនាំចេញរបស់តំបន់នេះ។ ភាពតានតឹងផ្នែកពាណិជ្ជកម្មនេះនឹងជះឥទ្ធិពលអវិជ្ជមានកាន់តែខ្លាំង តាមរយៈខ្សែចង្វាក់តម្លៃសកលក្នុងតំបន់។ ជាមួយគ្នានេះដែរ ភាពកាន់តែតានតឹងនៃពាណិជ្ជកម្មសកលនេះនឹងបង្កើនភាពមិនប្រាកដប្រជា ព្រមទាំងជះឥទ្ធិពលដល់សេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុសកល។

ហានិភ័យផ្សេងទៀតនាពេលដ៏ខ្លីខាងមុខ ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់តំបន់ រួមមានភាពតានតឹងកាន់តែខ្លាំងឡើងនៃភូមិសាស្ត្រនយោបាយ, កំណើនសេដ្ឋកិច្ចរបស់ក្រុមប្រទេស G3 ដែលយឺតជាងការរំពឹងទុក ក៏ដូចជាហានិភ័យនានា ដែលបណ្តាលមកពីការគាំពារពាណិជ្ជកម្ម។ ហានិភ័យនៃកំណើនយឺតជាងការរំពឹងទុករបស់សេដ្ឋកិច្ចចិនត្រូវបានវាយតម្លៃថា អាចនឹងមិនកើតឡើងនាពេលដ៏ខ្លីខាងមុខនោះទេ។ ជាចុងក្រោយ ហានិភ័យមិនមែនសេដ្ឋកិច្ចដែលតែងកើតឡើងជារឿយៗ រួមមានបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ព្រមទាំងការវាយប្រហារតាមអ៊ីនធើណែត (cyber-attacks)។

ភាពល្អប្រសើរឡើងនៃតម្រូវការពីតំបន់ខាងក្រៅ (external demand) បានធ្វើឱ្យតំបន់អាស៊ានបូកបីអាចបង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅដែលអាចកើតមាននាពេលអនាគត។ ដោយហេតុថាការចូលរួមរបស់បរទេសក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុកនៅក្នុងតំបន់អាស៊ានបូកបីមានកម្រិតខ្ពស់ ការដកភាគហ៊ុនបរទេសចេញពីទ្រព្យសកម្មរូបិយវត្ថុក្នុងស្រុក (local currency assets) និងលំហូរចេញនៃមូលធនភ្លាមៗ នៅក្នុង "សេណារីយ៉ូដែលវិនិយោគិនផ្លាស់ប្តូរការវិនិយោគពីតំបន់ដែលផ្តល់ទិន្នផលខ្ពស់ប៉ុន្តែប្រកបដោយហានិភ័យខ្ពស់ ទៅតំបន់ដែលមានហានិភ័យទាបបើទោះជាទទួលបានទិន្នផលទាបក៏ដោយ (risk-off scenario)" នឹងអាចដាក់សម្ពាធជាអវិជ្ជមានលើអត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ អត្រាប្តូរប្រាក់ក្នុងតំបន់ដែលប្រកបដោយភាពបត់បែនជាងមុន បានដើរតួនាទីកាន់តែសំខាន់ជាងមុន ក្នុងការកាត់បន្ថយការប៉ះទង្គិចផ្សេងៗ (shock absorber)។ ការធ្វើអន្តរាគមន៍ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អជ្ញាធរនៃបណ្តាប្រទេសនីមួយៗអាចជួយគ្រប់គ្រងល្បឿននៃការសម្របទៅនឹងការប៉ះទង្គិចពីខាងក្រៅ (pace of adjustment to external shocks) និងកាត់បន្ថយផលប៉ះពាល់ដល់សេដ្ឋកិច្ច។

អ្នករៀបចំគោលនយោបាយគួរបន្តកសាងគោលនយោបាយធំទូលាយ (policy space) ជាពិសេសគោលនយោបាយរូបិយវត្ថុ ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងការរឹតបន្តឹងកាន់តែខ្លាំងជាងមុននៃលក្ខខណ្ឌហិរញ្ញវត្ថុសកល។ ការអនុវត្តគោលនយោបាយចម្រុះ (policy mix) ដែលរួមមានគោលនយោបាយសារពើពន្ធ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្រុងប្រយ័ត្នម៉ាក្រូសេដ្ឋកិច្ច (macroprudential policies) គឺអាស្រ័យទៅលើស្ថានភាពបច្ចុប្បន្ននៃប្រទេសនីមួយៗ ថាតើវដ្តកំណើនសេដ្ឋកិច្ច និងវដ្តកំណើនឥណទាន (business and credit cycle) របស់ប្រទេសទាំងនោះ ស្ថិតក្នុងកម្រិត និងស្ថានភាពណា។

- ចំពោះប្រទេសដែលស្ថិតនៅក្នុងវដ្តកំណើនសេដ្ឋកិច្ចកម្រិតកណ្តាល (mid-business cycle) អ្នករៀបចំគោលនយោបាយពុំចាំបាច់បន្ថែមនូវកញ្ចប់រូបិយវត្ថុ ឬសារពើពន្ធសម្រាប់ជំរុញកំណើន (monetary or fiscal stimulus) នោះទេ។ តែផ្ទុយទៅវិញ ចំពោះប្រទេសដែលស្ថិតនៅក្នុងវដ្តកំណើនសេដ្ឋកិច្ចកម្រិតចុងក្រោយ (late-business cycle) ដែលមានការកើនឡើងនូវសម្ពាធអតិផរណា ឬអតុល្យភាពនៃវិស័យខាងក្រៅ អ្នករៀបចំគោលនយោបាយអាចពិចារណាកែប្រែគោលនយោបាយរូបិយវត្ថុ និងកាត់បន្ថយ

កញ្ចប់សារពើពន្ធសម្រាប់ជំរុញកំណើន (fiscal stimulus)។

- ដោយសារកំណើននៃឥណទានក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បើទោះជាប្រទេសភាគច្រើនក្នុងតំបន់នេះមានស្ថានភាពសេដ្ឋកិច្ចស្ថិតនៅក្នុងចន្លោះវដ្តកំណើនសេដ្ឋកិច្ចកម្រិតដំបូង និងកណ្តាល (early-to-mid-business cycle) ក៏ដោយ អ្នករៀបចំគោលនយោបាយគួរផ្តល់អាទិភាពទៅលើស្ថិរភាពហិរញ្ញវត្ថុនាពេលដ៏ខ្លីខាងមុខនេះ ជាជាងការផ្តោតសំខាន់តែទៅលើកំណើនសេដ្ឋកិច្ច ហើយគួររឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។

- ចំពោះប្រទេសណាដែលកំពុងប្រឈមនឹងការកើនឡើងនៃភាពងាយរងគ្រោះក្នុងវិស័យមួយចំនួន ដូចជាអចលនទ្រព្យ ការរឹតបន្តឹងគោលនយោបាយប្រុងប្រយ័ត្នម៉ាក្រូសេដ្ឋកិច្ចអាចជួយរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ប្រទេសភាគច្រើនក្នុងតំបន់បានរឹតបន្តឹងគោលនយោបាយប្រុងប្រយ័ត្នម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីបុរេសកម្ម។

- ដោយហេតុថាគោលនយោបាយរូបិយវត្ថុងាយនឹងទទួលរងឥទ្ធិពលពីការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយសកល គោលនយោបាយសារពើពន្ធនឹងអាចដើរតួនាទីកាន់តែសំខាន់ជាងមុន ក្នុងការជំរុញកំណើន ដែលអាចជួយកាត់បន្ថយភាពរឹតបន្តឹងខ្លាំងនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជារួម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការអនុវត្តគោលនយោបាយសារពើពន្ធនេះ ត្រូវតែមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយដល់លំហថវិកា (fiscal space) និងវិធានសារពើពន្ធ (fiscal rules) ផងដែរ។

- ចំពោះការរៀបចំគោលនយោបាយ ប្រទេសនីមួយៗក្នុងតំបន់ត្រូវតែគិតគូរឱ្យបានម៉ត់ចត់ ដោយពិចារណាដល់ឧបសគ្គនានា ដែលបណ្តាលមកពីភាពងាយរងគ្រោះទាំងក្នុងស្រុក និងក្រៅស្រុក ដូចជាការខ្ចីបំណុលបំពេញបន្ថែម (leverage) និងកម្រិតនៃការពឹងផ្អែកទៅលើហិរញ្ញប្បទានបរទេស។ គោលនយោបាយកែទម្រង់រចនាសម្ព័ន្ធគួរត្រូវបានបន្តអនុវត្ត ដើម្បីពង្រឹងសមត្ថភាពផលិតភាពនៃសេដ្ឋកិច្ច (productive capacity)។

## ប្រធានបទស្នូលៈ ភាពធន់ និងកំណើនសេដ្ឋកិច្ចក្នុងពិភពលោកដែលពោរពេញដោយការវិវត្ត

ជំពូកនេះធ្វើការសិក្សា ថាតើតំបន់អាស៊ានបូកបីនេះអាចរក្សាបាននូវភាពធន់ និងកំណើនបានដោយរបៀបណា ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរជាមូលដ្ឋាន និងសកលនៃបណ្តាញពាណិជ្ជកម្ម និងផលិតកម្ម ព្រមទាំងបច្ចេកវិទ្យា ក៏ដូចជាបញ្ហាប្រឈមប្រជាសាស្ត្រ។ តំបន់អាស៊ានបូកបីបានអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ (manufacturing for exports)" ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ប្រទេសដែលចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រនេះដំបូងគេក្នុងតំបន់ គឺជប៉ុន និងកូរ៉េ បន្ទាប់មកប្រទេសសមាជិកអាស៊ានធំៗមួយចំនួន និងប្រទេសសមាជិកអាស៊ានកំពុងអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ។ យុទ្ធសាស្ត្រនេះបានបង្កើតនូវវិបុលភាពសម្រាប់តំបន់ ដែលជួយ

ជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ ក៏ដូចជាបង្កើនផលិតភាព និងប្រាក់ឈ្នួល។ ការបង្កើតខ្សែចង្វាក់តម្លៃសកល (Global Value Chains) ដែលបានយកប្រទេសចិនធ្វើជាមូលដ្ឋានផលិតកម្មក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ បានធ្វើឱ្យប្រទេសក្នុងតំបន់អាចជំរុញការនាំចេញ និងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីលំហូរវិនិយោគផ្ទាល់ពីបរទេសសម្រាប់ការនាំចេញ (export-oriented FDI) ដើម្បីបង្កើនសមត្ថភាពកម្មន្តសាល (manufacturing capacity)។

យុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ" នេះ កំពុងតែប្រឈមនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធនៃខ្សែចង្វាក់តម្លៃសកលដែលកំពុងស្ថិតក្នុងស្ថានភាពទ្រឹង ស្របពេលដែលសមត្ថភាពផលិតភាពក្នុងស្រុក (domestic productive capacity) មានលក្ខណៈល្អប្រសើរជាងមុន ដែលអាចឱ្យប្រទេសនានាធ្វើការផលិត ជាជាងនាំចូលវត្ថុធាតុដើម។ ខ្សែចង្វាក់តម្លៃសកលអាចធ្វើឱ្យតំបន់អាស៊ានបូកបីទាំងមូល ក្លាយជាតំបន់មួយដែលមានសមត្ថភាពប្រកួតប្រជែងកាន់តែខ្លាំងជាងមុន ក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងក្លាយជាមូលដ្ឋានផលិតកម្មតំបន់ផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្សែចង្វាក់តម្លៃសកលនេះអាចជះឥទ្ធិពលអវិជ្ជមានកាន់តែខ្លាំងជាងមុនដល់ខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ទាំងមូល ដោយសារបញ្ហាប្រឈមរយៈពេលខ្លីមួយចំនួន ដែលរួមមានការគាំពារពាណិជ្ជកម្ម ជាដើម។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ការកើនឡើងនៃតម្រូវការចុងក្រោយក្នុងតំបន់ (intra-regional final demand) ដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយស្រូបយកនូវការនាំចេញនៅក្នុងតំបន់កាន់តែច្រើនជាងមុន ព្រមទាំងអាចជួយទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅដែលបណ្តាលមកពីការគាំពារពាណិជ្ជកម្ម។

បច្ចេកវិទ្យាត្រូវបានចាត់ទុកជាអាវុធមុខពីរ ដែលគំរាមកំហែងដល់ការអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ"។ ការប្រើប្រាស់បច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្ម (automation) នៅក្នុងវិស័យកម្មន្តសាល មានន័យថាវិស័យនេះនឹងមិនបង្កើតឱកាសការងារបានច្រើនដូចកាលពីមុនទៀតនោះទេ។ ករណីសិក្សានៃវិស័យយានយន្ត និងវិស័យកាត់ដេរក្នុងតំបន់ត្រូវបានលើកយកមកពិភាក្សាក្នុងជំពូកនេះផងដែរ។ ករណីសិក្សានេះបានបង្ហាញឱ្យឃើញថា ប្រទេសណា ដែលមិនបានបណ្តុះបណ្តាលជំនាញដល់ពលកររបស់ខ្លួន ក៏ដូចជាមិនបានពង្រឹងសមត្ថភាពដើម្បីចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ នឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានខ្លាំងជាង ក្នុងការរក្សាបាននូវភាពធន់ និងកំណើនសេដ្ឋកិច្ច។

ម៉្យាងវិញទៀត បច្ចេកវិទ្យាបានជួយសម្រួលដល់វិស័យសេវាកម្ម ដែលអាចក្លាយជាក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចថ្មីមួយ និងបង្កើតការងារ។ វិស័យសេវាកម្មត្រូវបានចាត់ទុកថា ជាវិស័យមួយដែលមានផលិតភាពទាប និងបង្កើតការងារដែលមានប្រាក់ចំណូលទាប។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើមានការប្រើប្រាស់បច្ចេកវិទ្យាត្រឹមត្រូវ វិស័យនេះនឹងក្លាយជាវិស័យមួយ ដែលមានផលិតភាពខ្ពស់ និងអាចបង្កើតការងារដែលមានប្រាក់ចំណូលខ្ពស់។ បច្ចេកវិទ្យាអាចជួយអភិវឌ្ឍវិស័យសេវាកម្ម តាមរយៈការធ្វើឱ្យវិស័យនេះអាចជួញដូរបានជុំវិញពិភពលោក និងបង្កើតឱកាសការងារជំនាញ ដូចដែលបានរៀបរាប់នៅក្នុងករណីសិក្សាស្តីពីកិច្ចដំណើរការធុរកិច្ចដោយប្រើប្រាស់ប្រភពធនធានពី

ខាងក្រៅ (Business Process Outsourcing)។ បច្ចេកវិទ្យាក៏បានធ្វើឱ្យ "សេវាកម្មក្លាយជាទំនិញដែលអាចជួញដូរបាន (commoditize)" និងធ្វើឱ្យ "ការប្រើប្រាស់សេវាកម្មមានភាពងាយស្រួលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាចល័ត (uberize)" ដែលការរីកចម្រើននៃបច្ចេកវិទ្យានេះ ជួយសម្រួលដល់ការកំណត់តម្រូវការទីផ្សារសេវាកម្ម និងជួយដល់ការកំណត់បច្ចេកវិទ្យាឱ្យត្រូវនឹងតម្រូវការទីផ្សារសេវាកម្ម ប្រកបដោយប្រសិទ្ធភាព ជាមួយនឹងតម្លៃសមរម្យ ដែលជាអត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់។ ទន្ទឹមនឹងនេះ កំណើនតម្រូវការសេវាកម្មក្នុងតំបន់ ដូចជាក្នុងវិស័យទេសចរណ៍ ក៏អាចបង្កើតនូវក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចផ្សេងទៀតផងដែរ។

ដើម្បីទាញយកនូវអត្ថប្រយោជន៍ពីតម្រូវការក្នុងតំបន់, បច្ចេកវិទ្យា និងវិស័យសេវាកម្ម ក៏ដូចជាដើម្បីពង្រឹងភាពធន់របស់ប្រទេសនីមួយៗ ព្រមទាំងតំបន់ទាំងមូល ការប្តេជ្ញាចិត្ត និងសកម្មភាពគោលនយោបាយពិតជាមានសារៈសំខាន់ណាស់។ អនុសាសន៍គន្លឹះសម្រាប់ប្រទេសនីមួយៗក្នុងតំបន់អាស៊ានបូកបី ដែលកំពុងប្រឈមនឹងការវិវត្តនៃពាណិជ្ជកម្ម, ផលិតកម្ម និងបច្ចេកវិទ្យា គឺការពង្រឹងភាពធន់ តាមរយៈការធ្វើពិពិធកម្មនៃក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ច ដែលរួមមានតាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍ ជាដើម។ សម្រាប់តំបន់អាស៊ានបូកបីទាំងមូល អនុសាសន៍គន្លឹះរួម គឺការពង្រឹងការតភ្ជាប់ និងសមាហរណកម្មក្នុងតំបន់ ដើម្បីបំពេញតម្រូវការចុងក្រោយក្នុងតំបន់។ ខណៈដែលតំបន់នេះនៅតែបន្តបើកចំហចំពោះពាណិជ្ជកម្ម និងវិនិយោគសកល ការពឹងផ្អែកទៅលើតម្រូវការក្នុងតំបន់ នឹងជួយពង្រឹងភាពធន់ក្នុងតំបន់ ដើម្បីទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ ឧទាហរណ៍ដូចជាការគាំពារពាណិជ្ជកម្ម ជាដើម។ ធនធានដ៏ច្រើនសន្ធឹកសន្ធាប់ និងភាពចម្រុះនៃការអភិវឌ្ឍក្នុងតំបន់អាស៊ានបូកបីទាំងមូល គឺជាប្រភពកម្លាំងដ៏រឹងមាំរបស់តំបន់នេះ។

- ការពង្រឹងការតភ្ជាប់តាមរយៈការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក និងក្នុងតំបន់ ជាមួយនឹងគោលនយោបាយសម្រួលពាណិជ្ជកម្មនានា អាចបង្កើនប្រសិទ្ធភាពនៃខ្សែចង្វាក់តម្លៃសកលក្នុងតំបន់ ហើយតាមរយៈការកាត់បន្ថយចំណាយពាក់ព័ន្ធនានា ក៏អាចធ្វើឱ្យតំបន់នេះកាន់តែមានភាពប្រកួតប្រជែងជាងមុនក្នុងការអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ"។ ដើម្បីពង្រឹងសមាហរណកម្មនៃខ្សែចង្វាក់តម្លៃសកល ការកាត់បន្ថយចំណាយលើការនាំចូលវត្ថុធាតុដើម គឺមានសារៈសំខាន់ប្រហាក់ប្រហែលនឹងការជំរុញការនាំចេញ ហើយការបង្កើតតំបន់សេដ្ឋកិច្ចពិសេស (Special Economic Zones) ក្នុងតំបន់ក៏អាចជួយសម្រួលដល់ការនាំចូលវត្ថុធាតុដើមដើម្បីកែច្នៃសម្រាប់ការនាំចេញផងដែរ។
- ដើម្បីអភិវឌ្ឍវិស័យសេវាកម្មឱ្យកាន់តែមានភាពរស់រវើក ប្រទេសនីមួយៗក្នុងតំបន់ត្រូវតែប្រកាន់ខ្ជាប់នូវគោលនយោបាយប្រកបដោយភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយចាប់ផ្តើមពីការពិនិត្យឡើងវិញនូវគោលនយោបាយណាដែលអាចជះឥទ្ធិពលអវិជ្ជមានដល់វិស័យសេវាកម្ម ហើយការអភិវឌ្ឍវិស័យសេវាកម្មនេះ គួរតែទទួលបាននូវការយកចិត្តទុកដាក់ប្រហាក់ប្រហែលនឹងការអភិវឌ្ឍវិស័យកម្មន្តសាលផងដែរ។ ការធ្វើសេរីភាវូបនីយកម្មវិស័យសេវាកម្មឱ្យចូលប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ នឹងអាចជួយ

បង្កើនផលិតភាពរបស់វិស័យនេះ ខណៈដែលបច្ចេកវិទ្យានឹងជួយជំរុញដល់ការធ្វើសេរីភាវូបនីយកម្មនេះ។

- ដោយហេតុថាវិស័យសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់ត្រូវការធនធានមនុស្ស និងកម្លាំងពលកម្មដែលមានជំនាញ ប្រទេសនីមួយៗក្នុងតំបន់គួរប្រើប្រាស់ធនធានមនុស្សដែលមានស្រាប់នៅក្នុងតំបន់ ដោយអនុវត្តគោលនយោបាយទេសន្តប្រវេសន៍ដែលសមរម្យ ដើម្បីជួយសម្រួលដល់លំហូរនៃកម្លាំងពលកម្មក្នុងតំបន់។ ជាមួយគ្នានេះផងដែរ តំបន់នេះត្រូវតែដោះស្រាយបញ្ហាប្រឈមនៃបច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្មដល់កម្លាំងពលកម្មដែលគ្មានជំនាញ តាមរយៈការអនុវត្តគោលនយោបាយអន្តរវិស័យប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដែលរួមមានគោលនយោបាយអភិវឌ្ឍកម្លាំងពលកម្មជំនាញ, គោលនយោបាយទេសន្តប្រវេសន៍ ដើម្បីទាញយកអត្ថប្រយោជន៍ពីការប្រើប្រាស់កម្លាំងពលកម្មជំនាញក្នុងតំបន់អាស៊ានបូកបី និងគោលនយោបាយអប់រំនានា។

*បញ្ជាក់: សេចក្តីសង្ខេបជាភាសាខ្មែរនេះ ត្រូវបានប្រែសម្រួលចេញពីសេចក្តីសង្ខេបដើមជាភាសាអង់គ្លេស ដែលអាចទាញយកបានតាមរយៈតំណភ្ជាប់នេះ (http://www.amro-asia.org/asean3-regional-economic-outlook-2018)។ សេចក្តីសង្ខេបនេះត្រូវបានប្រែសម្រួលយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីធានាភាពត្រឹមត្រូវស្របតាមសំណេរដើម ប៉ុន្តែប្រសិនបើមានកំហុសឆ្គង ឬខ្វះចន្លោះត្រង់ចំណុចណាមួយនោះ សេចក្តីសង្ខេបជាភាសាអង់គ្លេសត្រូវបានកំណត់យកជាគោល។*